ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៣៧៤ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ពន្ធលើចំណេញមូលធន

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងដាក់អនុវត្តពន្ធលើចំណេញមូលធនដែលសម្រេចបានដោយអ្នកជាប់ពន្ធ ស្រប តាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅដាក់ចេញនូវវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន ដែល សម្រេចបានដោយអ្នកជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលទទួលបានចំណេញមូលធន។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "អ្នកជាប់ពន្ធ" សំដៅដល់ អ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជន ដែលបានលក់ឬផ្ទេរ មូលធនទៅឱ្យបុគ្គលដទៃ។

២- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ រូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណវិនិច្ឆ័យចាប់ពីមួយឡើង ទៅក្នុងចំណោមលក្ខណវិនិច្ឆ័យទាំងបីដូចខាងក្រោម÷

- ក- មាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់
- ខ- មានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅ ដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិត នៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់
- គ- មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃក្នុងមួយលើកឬច្រើនលើក ក្នុងរយៈពេល ១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅនៅក្នុងព្រះរាជាណាចក្រ កម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា ១ថ្ងៃពេញ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខណ្ឌ ក និង វាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ វត្តមានរបស់រូបវន្តបុគ្គលដែលមានចែងក្នុងវាក្យខណ្ឌ គ គឺជាលក្ខខណ្ឌចុងក្រោយ សម្រាប់កំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គល។

៣- ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤- ពាក្យ "មូលធន" សំដៅដល់ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយវត្ថុបរទេស។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ពាក្យ÷

ក- អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ

ខ- ភតិសន្យា សំដៅដល់ ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់អចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬតាមតម្លៃសមមូល។ ភតិសន្យារួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ វៀរលែងតែភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុ និងភតិសន្យាពិសេសដែលមានចែងក្នុងច្បាប់ស្តីពីភតិសន្យាពិសេស

គ- ទ្រព្យវិនិយោគ សំដៅដល់ ភាគហ៊ុន សញ្ញាប័ណ្ណ និងមូលបត្រ ដែលបោះផ្សាយដោយសហគ្រាសឯកជន

ឃ- កេរ្តិ៍ឈ្មោះអាជីវកម្ម សំដៅដល់អាជ្ញាប័ណ្ណ បញ្ជីឈ្មោះអតិថិជន និងយីហោ

ង- កម្មសិទ្ធិបញ្ញា រួមមាន តក្កកម្ម ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ និមិត្តសញ្ញា រូបភាពនិងគំនូរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម

ច- រូបិយវត្ថុបរទេស សំដៅដល់រូបិយប័ណ្ណក្រៅពីប្រាក់រៀល។

៥- ពាក្យ "ចំណេញមូលធន" សំដៅដល់ ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត។

## ប្រការ ៥.- ការលើកលែងពន្ធ

ពន្ធលើចំណេញមូលធន ត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរ÷

១- ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ។

២- ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ។

៣- និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងតិចប្រាំ (៥) ឆ្នាំមុនពេលលក់ឬផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានជាគោលដើម។

៤- អចលនទ្រព្យក្នុងវង្វង់ញាតិដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត រវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ និងរវាងយាយ-តាក្មេកនិងចៅប្រសារ។

៥- ទ្រព្យដែលត្រូវបានលក់ឬផ្ទេរដើម្បីបម្រើប្រយោជន៍សាធារណៈ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

## ប្រការ ៦.- ពេលសម្រេចបានចំណេញមូលធន

សម្រាប់គោលដៅនៃប្រកាសនេះ អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធន នៅពេល÷

១- លក់ឬផ្ទេរ ឬបង្កើតឱ្យមានសិទ្ធិគ្រប់គ្រងលើទ្រព្យ ឬ

២- ចុះបញ្ជីសម្រាប់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យនៅអាជ្ញាធរមានសមត្ថកិច្ច ឬ

៣- ពេលសម្រេចផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

## ប្រការ ៧.- ចំណាយដែលអាចកាត់កងបាន

ចំណាយដែលអាចអនុញ្ញាតឱ្យកាត់កងបាន ត្រូវបំពេញនូវលក្ខខណ្ឌទាំងបីដូចខាងក្រោម÷

១- ហេតុការណ៍ដែលបញ្ជាក់អំពីការកើតឡើងនូវបន្ទុក ឬចំណាយ ដែលមានភ័ស្តុតាងអាចត្រួតពិនិត្យបាន

២- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងចំណាយ

៣- មានវិក្កយបត្រ ឬឯកសារភ័ស្តុតាងបញ្ជាក់អំពីចំនួនទឹកប្រាក់ដែលបានចំណាយ។

## ប្រការ ៨.- វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយ ត្រូវបានកំណត់ដូចខាងក្រោម÷

១- ចំពោះមូលធនជាអចលនទ្រព្យ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីទាំងពីរដូចខាងក្រោម÷

ក- វិធីកាត់កងចំណាយតាមការកំណត់÷ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយ ៨០ ភាគរយនៃប្រាក់ចំណូលដែលទទួលបានពីការលក់ឬផ្ទេរទ្រព្យ

ខ- វិធីកាត់កងតាមចំណាយជាក់ស្តែង÷ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយដែលបានកើតឡើងជាក់ស្តែង។

២- ចំពោះមូលធនដទៃទៀត អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយ តែតាមវិធីកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធជ្រើសរើសវិធីកាត់កងតាមចំណាយជាក់ស្តែង ហើយចំណាយដែលបានកើតឡើងជាក់ស្តែងមានចំនួនច្រើនជាងចំណូលពីការលក់ឬផ្ទេរទ្រព្យ ចំនួនលើសមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបង្វិលសង ឬយកទៅកាត់កងចេញពីចំណេញមូលធននៃទ្រព្យដទៃទៀតទេ។

## ប្រការ ៩.- ថ្លៃលក់ និងថ្លៃដើមនៃទ្រព្យ

ដើម្បីគណនាពន្ធលើចំណេញមូលធន ថ្លៃលក់និងថ្លៃដើមនៃទ្រព្យ ត្រូវកំណត់ដូចខាងក្រោម÷

១- ថ្លៃលក់នៃទ្រព្យ ត្រូវគិតតាមតម្លៃលក់ឬផ្ទេរទ្រព្យដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាទិញ-លក់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធរកឃើញថាថ្លៃលក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាទិញ-លក់ មានតម្លៃទាបជាងតម្លៃទីផ្សារ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវថ្លៃលក់នៃទ្រព្យ ដោយឈរលើតម្លៃទីផ្សារ ឬតម្លៃដែលកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬតម្លៃដែលកំណត់ដោយគណៈកម្មការវាយតម្លៃទ្រព្យនៃពន្ធលើចំណេញមូលធន។

២- ថ្លៃដើមនៃទ្រព្យរួមមាន ថ្លៃដើមពេលទិញទ្រព្យ និងចំណាយដែលបានកើតឡើងក្នុងពេលទិញឬទទួល កាន់កាប់ លក់ឬផ្ទេរទ្រព្យ ដែលជាអាទិ៍មាន÷

ក- ចំណាយលើសេវាពិគ្រោះយោបល់

ខ- ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់នៅពេលទិញឬទទួលទ្រព្យ

គ- ប្រាក់ពន្ធលើអចលនទ្រព្យ ឬប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលបានបង់

ឃ- ចំណាយលើសេវារដ្ឋបាលសុរិយោដីឬភូមិបាល

ង- ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម

ច- ចំណាយកម្រៃជើងសា

ឆ- ចំណាយលើការវាយតម្លៃទ្រព្យ

ជ- ចំណាយលើសេវារដ្ឋបាលចំពោះការខ្ចីប្រាក់ដើម្បីទិញឬទទួលទ្រព្យ

ឈ- ចំណាយការប្រាក់ចំពោះការខ្ចីប្រាក់ដើម្បីទិញទ្រព្យដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ

ញ- ចំណាយថែទាំនិងកែលម្អទ្រព្យ

ដ- ចំណាយក្នុងការបង្កើតឬរក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ។

**ប្រការ ១០.- អត្រាពន្ធ**

អត្រាពន្ធលើចំណេញមូលធន ត្រូវបានកំណត់តាមអត្រាថេរ ២០%។

**ប្រការ ១១.- ការគណនាចំណេញមូលធន**

អនុលោមតាមប្រការ ៨ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីគណនាចំណេញមូលធនណាមួយក្នុងចំណោមវិធីទាំងពីរ ដូចខាងក្រោម÷

១- វិធីកាត់កងចំណាយតាមការកំណត់

**ឧទាហរណ៍ ១១.១**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៨០០ ០០០ ០០០ រៀល។ លោក **ក** មិនបានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងផ្ទះល្វែងនោះ។ ដូចនេះ លោក **ក** អាចជ្រើសយកវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម÷

| | |
|---|---|
| ចំណូលពីការលក់ឬផ្ទេរទ្រព្យ | = ៨០០ ០០០ ០០០ រៀល |
| ការកាត់កងចំណាយតាមការកំណត់ | = ៨០% x ចំណូលពីការលក់ឬផ្ទេរទ្រព្យ |
| | = ៨០% x ៨០០ ០០០ ០០០ |
| | = ៦៤០ ០០០ ០០០ រៀល |
| ចំណេញមូលធន | = ចំណូលពីការលក់ឬផ្ទេរទ្រព្យ - ចំណាយតាមការកំណត់ |
| | = ៨០០ ០០០ ០០០ - ៦៤០ ០០០ ០០០ |
| | = <u>១៦០ ០០០ ០០០ រៀល</u> |

២- វិធីកាត់កងតាមចំណាយជាក់ស្តែង

**ឧទាហរណ៍ ១១.២**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៦០០ ០០០ ០០០ រៀល ដែលបានទិញក្នុងតម្លៃ ៤០០ ០០០ ០០០ រៀល ដោយបានបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនវត្ថុ ១៦ ០០០ ០០០ រៀល បានចំណាយកម្រៃជើងសាសម្រាប់ការលក់ផ្ទះ ២៤ ០០០ ០០០ រៀល និងបានចំណាយជួសជុលកែលម្អផ្ទះ ២០ ០០០ ០០០ រៀល។

លោក ឥ បានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងការកាន់កាប់ និងកែលម្អផ្ទះល្វែងនោះ។ ដូចនេះ លោក ឥ អាចជ្រើសយកវិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម÷

ចំណូលពីការលក់ឬផ្ទេរទ្រព្យ= ៦០០ ០០០ ០០០

ចំណាយជាក់ស្តែងសរុប = ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ

= ៤០០ ០០០ ០០០ + ១៦ ០០០ ០០០ + ២៤ ០០០ ០០០ + ២០ ០០០ ០០០

= ៤៦០ ០០០ ០០០ រៀល

ចំណេញមូលធន = ចំណូលពីការលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប

= ៦០០ ០០០ ០០០ - ៤៦០ ០០០ ០០០

= <u>១៤០ ០០០ ០០០ រៀល</u>

**ប្រការ ១២.- ការគណនាពន្ធលើចំណេញមូលធន**

ពន្ធលើចំណេញមូលធន ត្រូវបានគណនាដោយយកចំណេញមូលធន គុណនឹងអត្រាពន្ធដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។

**ឧទាហរណ៍ទី ១២.១**

លោក ឥ ជាអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ផ្ទះល្វែងចំនួន ៣៤០ ០០០ ០០០ រៀល។

ពន្ធលើចំណេញមូលធន = ចំណេញមូលធន x អត្រាថេរ ២០%

= ៣៤០ ០០០ ០០០ x ២០%

= <u>៦៨ ០០០ ០០០ រៀល</u>

**ឧទាហរណ៍ទី ១២.២**

លោក ខ ជាអ្នកជាប់ពន្ធអនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ភាគហ៊ុនក្នុងក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា ចំនួន ៤០០ ០០០ ០០០ រៀល។

ពន្ធលើចំណេញមូលធន = ចំណេញមូលធន x អត្រាថេរ ២០%

= ៤០០ ០០០ ០០០ x ២០%

= <u>៨០ ០០០ ០០០ រៀល</u>

**ប្រការ ១៣.- ពន្ធលើចំណេញមូលធនចំពោះទ្រព្យនៅក្រៅព្រះរាជាណាចក្រកម្ពុជា**

ក្នុងករណីដែលអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីទ្រព្យណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងបានបង់ពន្ធលើចំណេញមូលធនតាមច្បាប់ពន្ធដារបរទេសរួចហើយ ប្រសិនបើប្រាក់ពន្ធនៅបរទេសនោះ មានចំនួនតិចជាងប្រាក់ពន្ធដែលគណនាតាមប្រការ ១២ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមតែចំនួនលម្អៀងប៉ុណ្ណោះ។

**ប្រការ ១៤.- ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ**

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធន តាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី ០៣ខែបន្ទាប់ពីសម្រេចបានចំណេញមូលធនដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះទ្រព្យដែលស្ថិតនៅតាមបណ្តាខេត្ត អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅសាខាពន្ធដារខេត្តដែលទ្រព្យស្ថិតនៅ។

**ប្រការ ១៥.- ឯកសារតម្រូវ**

អ្នកជាប់ពន្ធត្រូវផ្តល់នូវឯកសារពាក់ព័ន្ធ សម្រាប់ការបង់ពន្ធលើចំណេញមូលធន ដូចខាងក្រោម÷

ក- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស

ខ- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

គ- លិខិតបញ្ជាក់របស់អ្នកជាប់ពន្ធ អំពីការកំណត់និវាសនដ្ឋានជាគោលដើមរបស់ខ្លួន

ឃ- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ឬឯកសារបញ្ជាក់ការទទួលស្គាល់របស់ស្ថាប័នមានសមត្ថកិច្ច

ង- កិច្ចសន្យាទិញ-លក់ទ្រព្យ ឬកិច្ចសន្យាដោះដូរឬអំណោយ

ច- វិក្កយបត្រទូទាត់ប្រាក់ និងវិក្កយបត្រចំណាយផ្សេងៗដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

ឆ- ឯកសារដទៃទៀតពាក់ព័ន្ធនឹងការលក់ឬផ្ទេរមូលធន។

**ប្រការ ១៦.- សិទ្ធិក្នុងការត្រួតពិនិត្យ**

រដ្ឋបាលសារពើពន្ធមានសិទ្ធិត្រួតពិនិត្យ ដើម្បីធ្វើការកំណត់ឡើងវិញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ពន្ធត្រូវបង់ក្នុងករណីដែលអ្នកជាប់ពន្ធមិនផ្តល់ឯកសារពាក់ព័ន្ធត្រឹមត្រូវ។

**ប្រការ ១៧.- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធន**

រាល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធនមិនមានលក្ខណៈគតិយុត្តគ្រប់គ្រាន់ទេ ក្នុងករណីដែលមូលធននោះមិនទាន់មានការបញ្ជាក់ពីការបង់ពន្ធលើចំណេញមូលធន។

**ប្រការ ១៨.- ការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន**

ពន្ធលើចំណេញមូលធន ត្រូវចាប់អនុវត្តលើចំណេញមូលធនដែលកើតមានឡើងចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ តទៅ។

**ប្រការ ១៩.- ទោសទណ្ឌ**

អ្នកជាប់ពន្ធត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន ក្នុងករណីមិនបានដាក់លិខិតប្រកាសនិងបង់ពន្ធលើចំណេញមូលធនតាមពេលកំណត់។

**ប្រការ ២០.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ ៧ កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ២០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ